INTERNAL AUDIT UNIT
អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ១៧ ចេញផ្សាយ ខែឧសភា ឆ្នាំ២០២៣

# ភាពសន្សំសំចៃប្រតិបត្តិការ

### ១. និដ្ឋភាពទូទៅនៃប្រតិបត្តិការ

ប្រតិបត្តិការ សំដៅសកម្មភាពទាំងឡាយណាដែលផ្តោតលើការផលិតទំនិញ ឬសេវាកម្ម។ មុខងារប្រតិបត្តិការរាប់បញ្ចូលដំណើរការក្នុងការបំលែងវត្ថុធាតុដើមទៅជាផលិតផលសម្រេច។

ក្នុងន័យទូទៅ ប្រតិបត្តិការ សំដៅដល់ដំណើរការសកម្មភាពណាមួយដែលស្ថាប័នអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលជាក់លាក់មួយ។

***មុខងារសំខាន់ៗរបស់ប្រតិបត្តិការ រួមមាន៖***

*១. ការតាមដានត្រួតពិនិត្យការអនុវត្តរបស់មន្ត្រីទទួលបន្ទុកអនុវត្តការងារ*

*២. ការបញ្ជូនការណែនាំ និងការសម្រេចចិត្តពីថ្នាក់ដឹកនាំទៅមន្ត្រីទទួលបន្ទុកអនុវត្តការងារ*

*៣. ការធានាគុណភាព*

*៤. ការកាត់បន្ថយហានិភ័យ*



### ២. ការចំណាយចំពោះការគ្រប់គ្រងប្រតិបត្តិការ

នៅពេលដែលស្ថាប័នដាក់ឱ្យដំណើរការប្រតិបត្តិការអ្វីមួយ តែងតែទាមទារឱ្យមាននូវការចំណាយលើការគ្រប់គ្រងប្រតិបត្តិការ ដែលការចំណាយចំពោះការគ្រប់គ្រងប្រតិបត្តិការត្រូវបានបែងចែកជា ២ (ពីរ) ប្រភេទ រួមមាន៖

### ក. ចំណាយជាក់ស្តែង

ចំណាយជាក់ស្តែង សំដៅដល់ចំណាយដែលទ្រទ្រង់ប្រតិបត្តិការរបស់ស្ថាប័នផ្ទាល់ រួមមាន ចំណាយលើរចនាសម្ព័ន្ធស្ថាប័ន ចំណាយប្រាក់បៀវត្សមន្ត្រី ចំណាយលើការរៀបចំប្រព័ន្ធត្រួតពិនិត្យ ចំណាយសម្រាប់ការអនុវត្តសកម្មភាពណាមួយ ចំណាយសម្ភារៈបរិក្ខារ និងចំណាយប្រេង អគ្គិសនី និងទឹក។

### ខ. ចំណាយឱកាស

ចំណាយឱកាស សំដៅដល់ចំណាយទៅលើជម្រើស ឬឱកាសផ្សេងទៀតដែលត្រូវលះបង់ ដើម្បីអាចជ្រើសរើស ឬដាក់ឱ្យប្រតិបត្តិការមួយដំណើរការ។ រាល់ការដាក់ឱ្យដំណើរការប្រតិបត្តិការទាំងអស់តែងតែមាននូវចំណាយឱកាស។ ប្រសិនបើស្ថាប័នពុំដាក់ឱ្យដំណើរការនូវប្រតិបត្តិការណាមួយដែលបានជ្រើសរើសនោះទេ ស្ថាប័នអាចនឹងប្រើប្រាស់ធនធានដែលត្រូវចំណាយនោះ លើប្រតិបត្តិការណាផ្សេងទៀត។

### ៣. ភាពសន្សំសំចៃ

### ៣.១. និយមន័យ

***ភាពសន្សំសំចៃ*** គឺជាការធ្វើអប្បបរមាថ្លៃដើមនៃធនធាន ដែលធនធានត្រូវបានប្រើប្រាស់គួរតែមានក្នុងកំឡុងពេលកំណត់មួយ ប្រកបដោយគុណភាព និងបរិមាណសមស្រប ព្រមទាំងមានតម្លៃល្អសមរម្យ។

ទស្សនាទានលើភាពសន្សំសំចៃ បានពន្យល់យ៉ាងច្បាស់ពីការអនុវត្តការងារប្រកបដោយ ភាពសន្សំសំចៃ

អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ១៧ ចេញផ្សាយ ខែឧសភា ឆ្នាំ២០២៣

## ភាពសន្សំសំចៃប្រតិបត្តិការ

ជារឿងចាំបាច់សម្រាប់ស្ថាប័នសាធារណៈទាំងអស់។ ជារឿយៗ បញ្ហាប្រឈមដ៏លំបាកសម្រាប់ស្ថាប័នសាធារណៈ គឺធ្វើយ៉ាងណាប្រើប្រាស់ថវិកាសាធារណៈប្រកបដោយភាពសន្សំសំចៃ។

ធនធាន សំដៅដល់ហិរញ្ញវត្ថុ សម្ភារៈមនុស្ស និងទ្រព្យសម្បត្តិផ្សេងៗ ដែលស្ថាប័នមានតម្រូវការប្រើប្រាស់ដើម្បីគាំទ្រដល់ដំណើរការរបស់ស្ថាប័ន។

### ៣.១. ការសន្សំសំចៃធនធានហិរញ្ញវត្ថុ

ការប្រើប្រាស់ថវិកាជាអប្បបរមា និងមានភាពសន្សំសំចៃ ប៉ុន្តែសម្រេចបានគោលដៅដែលបានកំណត់ ជាពិសេសស្ថាប័នត្រូវគិតពិចារណាថា តើត្រូវចំណាយទិញទំនិញឬសេវាដែលមានតម្លៃទាប ឬក៏នៅពេលដែលស្ថាប័នមានតម្រូវការចាំបាច់នូវធនធានទាំងនោះដើម្បីប្រើប្រាស់។

**ឧទាហរណ៍÷** ស្ថាប័នអាចជ្រើសរើសការធ្វើលទ្ធកម្មដើម្បីទទួលបានទំនិញ ឬសេវាដែលមានតម្លៃសមរម្យ និងគុណភាពល្អ។




### ៣.២. ការសន្សំសំចៃលើធនធានមិនមែនហិរញ្ញវត្ថុ

ការជ្រើសរើសត្រូវនូវធនធានមនុស្ស ឬធនធានសម្ភារៈ សម្រាប់គាំទ្រតម្រូវការក្នុងដំណើរការរបស់ស្ថាប័ន។ **ឧទាហរណ៍÷** ស្ថាប័នអាចសន្សំសំចៃលើធនធានមនុស្ស តាមរយៈ ការជ្រើសរើសត្រូវ ការរៀបចំបណ្តុះបណ្តាលត្រូវ ការប្រើប្រាស់ត្រូវ និងការទុកដាក់ត្រូវ។ ក្នុងន័យនេះ ស្ថាប័នត្រូវជ្រើសរើសមន្ត្រី ដែលមានសមត្ថភាពស្របតាមតម្រូវការរបស់ស្ថាប័ន រៀបចំការបង្កើនសមត្ថភាពមន្ត្រី បែកចែកតួនាទីភារកិច្ចមន្ត្រីទៅតាមជំនាញ គុណវុឌ្ឍិ និងបទពិសោធន៍។ ជាពិសេសគឺការទុកដាក់ត្រូវ សំដៅដល់ការលើកទឹកចិត្តមន្ត្រី តាមរយៈ ការផ្តល់ការឧបត្ថម្ភ និងការតែងតាំងមុខតំណែងស្របតាមសមត្ថភាព និងអតីតភាពការងារ ជៀសវាងការបាត់បង់មន្ត្រីដែលមានបទពិសោធន៍ និងសមត្ថភាព និងជ្រើសរើសមន្ត្រីថ្មីដែលទាមទារក្នុងការបណ្តុះបណ្តាលបន្ថែម។

**អត្ថបទ÷** លោក **រតនា បញ្ញាសម្បត្តិ**

**ឯកសារយោង÷**

១- ឧត្តមានុវត្តន៍នៃការគ្រប់គ្រងប្រតិបត្តិការរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**

២- សេចក្តីណែនាំស្តីពីយន្តការ និងនីតិវិធីនៃការធ្វើសវនកម្មសមិទ្ធកម្មរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**

៣- គោលការណែនាំស្តីពីសវនកម្មសមិទ្ធកម្មរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.**

៤- ចក្ខុវិស័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ២០៣០

អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.

ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

Facebook Telegram Website